# ការបង្ការវីរុសកូរ៉ូណា (ខូវីដ-១៩)៖

## *លក្ខខណ្ឌតម្រូវទូទៅនៃកន្លែងធ្វើការ - សេចក្តីសង្ខេប*

*Department of Labor & Industries (ក្រសួងការងារនិងឧស្សាហកម្ម) (L&I) តម្រូវឱ្យនិយោជកផ្តល់កន្លែងធ្វើការដែលមានសុវត្ថិភាពនិងសុខមាលភាពល្អ និងអនុវត្តបទបញ្ជារបស់អភិបាលក្នុងការបង្ការការរីករាលដាលនៃវីរុសកូរ៉ូណា។*

## លក្ខខណ្ឌតម្រូវទូទៅចាំបាច់សម្រាប់និយោជក

### ការរក្សាគម្លាតរាងកាយ

- ធានាថានិយោជិករក្សាបាននូវគម្លាតយ៉ាងតិចប្រាំមួយហ្វីតពីមិត្តរួមការងារនិងសាធារណជន នៅពេលដែលអាចធ្វើទៅបាន។
- ប្រសិនបើការរក្សាគម្លាតរាងកាយមិនអាចធ្វើទៅបានទេ ចូរប្រើរបាំងនិងវិធីសាស្រ្តបង្ការផ្សេងទៀតដែលត្រូវបានឯកភាព ដើម្បីការពារការឆ្លងវីរុសកូរ៉ូណា។
- ធានាបាននូវការប្រើប្រាស់ក្រណាត់បាំងមុខ ម៉ាស់ ឬឧបករណ៍ដកដង្ហើម ប្រសិនបើមិនអាចរក្សាគម្លាតរាងកាយបាន។

### ការលាងដៃញឹកញាប់និងគ្រប់គ្រាន់

- ផ្តល់ជូននូវកន្លែងលាងដៃចល័តឬអចល័តដែលមានទឹកស្អាតនិងក្តៅឬឧណ្ឌៗ សាប៊ូ និងក្រដាសជូត។
- តម្រូវឱ្យលាងដៃពេលមកដល់កន្លែងធ្វើការ ធ្វើការសម្រាក ប្រើបន្ទប់ទឹក មុននិងក្រោយពេលបរិភោគ ផឹក ឬប្រើប្រាស់ផលិតផលថ្នាំជក់ និងក្រោយពេលប៉ះផ្ទៃដែលមានជាតិកខ្វក់។
- ផ្តល់ជូននូវស្ថានីយ៍/បរិក្ខារផ្គត់ផ្គង់ផ្នែកអនាម័យ ប្រដាប់ជូត ឬកន្សែងជូតនៅក្នុងធុងចល័ត ដើម្បីជួយសម្រួលដល់ការរក្សាអនាម័យដៃឱ្យបានញឹកញាប់ (ចន្លោះការលាងដៃ)
បន្ទាប់ពីចាប់កាន់វត្ថុដែលប៉ះដោយអ្នកដទៃ។

### ការសម្អាតនិងរក្សាអនាម័យជាទៀតទាត់និងបន្ថែម

- បង្កើតកាលវិភាគរៀបចំគេហដ្ឋានដែលរួមមានការសម្អាតនិងរក្សាអនាម័យឱ្យបានញឹកញាប់។
- ធានាបាននូវការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់សម្រាប់ការសម្អាតនិងរក្សាអនាម័យលក្ខណៈស៊ីជម្រៅ បន្ទាប់ពីមានករណីសង្ស័យអំពីជំងឺខូវីដ-១៩។
- រម្ងាប់មេរោគលើផ្ទៃដែលត្រូវប៉ះពាល់ញឹកញាប់។

- ធានាបានថានិយោជិតប្រើស្រោមដៃការពារនិងឧបករណ៍ការពារភ្នែក/មុខ នៅពេលប្រើប្រាស់សារធាតុគីមី។
- ធានាបានថាយានជំនិះការងាររួមគ្នាត្រូវបានសម្អាតនិងរម្ងាប់មេរោគរាល់ពេលមានអ្នកប្រើប្រាស់ខុសៗគ្នាប្រើយានជំនិះនោះ និងជាទៀងទាត់ ប្រសិនបើមនុស្សដដែលប្រើវា។
- រក្សាទុកបញ្ជីទិន្នន័យសុវត្ថិភាព (SDSs) សម្រាប់ទឹករម្ងាប់មេរោគទាំងអស់នៅនឹងកន្លែង។

## បង្កើតនីតិវិធីសម្រាប់កម្មករនិយោជិតឈឺ

- តម្រូវឱ្យកម្មករនិយោជិតដែលឈឺស្នាក់នៅផ្ទះឬនៅដាច់ដោយឡែក ប្រសិនបើពួកគេរស់នៅក្នុងកសិដ្ឋាន។
- កំណត់អត្តសញ្ញាណនិងបញ្ជូនទៅផ្ទះឬដាក់ដោយឡែកនូវកម្មករនិយោជិតដែលមានរោគសញ្ញានៃជំងឺខូវីដ-១៩។
- ហ៊ុំព័ទ្ធបិទតំបន់នោះជាបណ្តោះអាសន្ន រហូតទាល់តែត្រូវបានសម្អាតនិងធ្វើអនាម័យលក្ខណៈស៊ីជម្រៅ បន្ទាប់ពីមានការរាយការណ៍អំពីនិយោជិតដែលមានការសង្ស័យឬបញ្ជាក់ថាពិតជាឆ្លងជំងឺខូវីដ-១៩។

## ការអប់រំនិយោជិតអំពីគ្រោះថ្នាក់នៅកន្លែងធ្វើដោយជំងឺខូវីដ-១៩

ជាភាសាដែលយល់យ៉ាងច្បាស់ដោយនិយោជិត ចូរធានាថាពួកគេដឹងអំពី៖

- សញ្ញា រោគសញ្ញា និងកត្តាហានិភ័យដែលទាក់ទងនឹងជំងឺខូវីដ-១៩។
- វិធីការពារការរីករាលដាលនៃវីរុសកូរ៉ូណានៅកន្លែងការងារ។
- វិធីលាងដៃឱ្យប្រកបដោយប្រសិទ្ធិភាពជាមួយសាប៊ូនិងទឹកយ៉ាងហោចណាស់ ២០ វិនាទី។
- សារៈសំខាន់នៃការបិតបាំងពេលក្អកនិងកណ្តាស់ និងការដែលមិនត្រូវប៉ះមុខដោយដៃមិនបានលាង។

* នេះគឺជាសេចក្តីសង្ខេប។ សម្រាប់សេចក្តីលម្អិត សូមមើលឯកសារលេខ F414-164-000 *Coronavirus (COVID-19) Prevention: General Requirements and Prevention Ideas for Workplaces* (ការបង្ការវីរុសកូរ៉ូណា(ខូវីដ-១៩)៖ លក្ខខណ្ឌតម្រូវទូទៅនិងគំនិតបង្ការសម្រាប់កន្លែងធ្វើការ)។